ធ៥-០១០-៤៨៦ ស.ជ.ណ

ភ្នំពេញ, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១០

**ជម្រាបមក**

**លោកនាយក សាខាធនាគារជាតិនៃកម្ពុជាខេត្ត ដែលមានសភាផាត់ទាត់**

**កម្មវត្ថុ:** ការយកកម្រៃសេវាសភាផាត់ទាត់ប្រចាំឆ្នាំ និងប្រាក់ផាកពិន័យមូលប្បទានប័ត្របញ្ជូនត្រឡប់នៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត

**យោង:** វិធាន និង នីតិវិធីសម្រាប់សភាផាត់ទាត់ធនាគារជាតិនៃកម្ពុជា

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយលសូមជម្រាបជូន លោកនាយកសាខាធនាគារជាតិនៃកម្ពុជាខេត្ត ដែលមានសភាផាត់ទាត់ឱ្យបានជ្រាបថា ដើម្បីឱ្យស្របតាមវិធាន និងនីតិវិធីសម្រាប់សភាផាត់ទាត់ធនាគារជាតិនៃកម្ពុជា ឧបសម្ព័ន្ធ៧ ស្តីពីការយកកម្រៃសេវាសភាផាត់ទាត់ ធនាគារជាតិនៃកម្ពុជាកំណត់យកកម្រៃសេវាសភាផាត់ទាត់ប្រចាំឆ្នាំ និងប្រាក់ផាកពិន័យមូលប្បទានប័ត្របញ្ជូនត្រឡប់ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក គឺ៖

១- កម្រៃសេវាសភាផាត់ទាត់មូលប្បទានប័ត្រជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ចំនួន ៣.២០០.០០០ រៀល ក្នុងមួយឆ្នាំ ដូចគ្នា។

២- ការផាកពិន័យមូលប្បទានប័ត្របញ្ជូនត្រឡប់ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក គឺ ៨.០០០ រៀល ក្នុងមួយសន្លឹក ដូចគ្នា។

កម្រៃសេវាប្រចាំឆ្នាំ និងប្រាក់ផាកពិន័យមូលប្បទានប័ត្របញ្ជូនត្រឡប់នេះ នឹងចាប់អនុវត្តពីឆ្នាំ ២០១១ តទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោកនាយកជ្រាប និងធ្វើការជូនដំណឹងដល់សាខាធនាគារពាណិជ្ជជាសមាជិកសភាផាត់ទាត់ដើម្បីសហការអនុវត្ត។

សូមលោកនាយក ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយក**

**តាល់ ណៃអ៊ីម**